90/6

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ២៦១

ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១២

សាលដីកា

លេខ: ៣៣៦

ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម:

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោកស្រី [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ១៧ "ក្រVIសវ" ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ២៦១ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១២ របស់តុលាការកំពូល។

ពីបទ: ប្លន់ (ម៉ូតូ) ប្រព្រឹត្តនៅចំណុចព្រះអង្គដងកើ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ (នៅក្នុងឃុំ)

-ជនជាប់ចោទ៖

១.ឈ្មោះ [redacted] រតនៈ "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិ ទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។



Scanned by CamScanner

២.ឈ្មោះ[redacted]ុភាវុធ "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះ លេខ៣៦១D ផ្លូវលេខ៦៨ ភូមិ៥ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

-មានលោ[redacted] ចន្ថា ជាមេធាវីការពារ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ណា ភេទប្រុស ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ២៣៥ ផ្លូវមុនីវង្ស សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ "ម្ចាស់បណ្តឹងសាទុក្ខ"។

-កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ នៅចំនុចព្រះអង្គដងកើ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានករណីប្លន់ (វាយយកម៉ូតូ) មួយកើតឡើង ដែលបង្កឡើងដោយជនល្មើសឈ្មោះ[redacted] រតនៈ និងឈ្មោះ[redacted] សុភាវុធ ព្រមទាំងបក្សពួក៦នាក់ទៀត បានធ្វើសកម្មភាពវាយយកម៉ូតូរបស់ជនរងគ្រោះឈ្មោះ[redacted] ចាន់ណា បណ្តាលឱ្យជនរងគ្រោះត្រូវរបួស ភ្លាមនោះជនរងគ្រោះក៏បានផ្តួលម៉ូតូចោល ហើយរត់គេចខ្លួន ហើយជនល្មើសឈ្មោ[redacted] រតនៈ បំរុងលើកម៉ូតូជនរងគ្រោះជិះចេញ ក៏ត្រូវសមត្ថកិច្ចមកដល់ឃាត់ខ្លួនបានឈ្មោះ [redacted] រតនៈ រីឯបក្សពួករបស់ជនល្មើសផ្សេងទៀតបានរត់គេចខ្លួនអស់តែម្តង។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា៖

+បញ្ជូនជនត្រូវចោទឈ្មោះ [redacted] រតនៈ ភេទប្រុស អាយុ១៩ឆ្នាំ ទៅជំនុំជម្រះតាមច្បាប់។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៥៨ កប៣ "អ" ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេច៖

១-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] រតនៈ ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ ទីលំនៅមុនពេលចាប់ខ្លួនផ្ទះលេខ៣០០S ផ្លូវលំ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោ[redacted] "ស" កំរិតវប្បធម៌ថ្នាក់ទី៧ ទោសពីមុនគ្មាន។

ខ-ឈ្មោះ [redacted]សុភាវុធ ភេទប្រុស អាយុ២១ឆ្នាំ មានទីលំនៅមុនពេលចាប់ខ្លួន ផ្ទះលេខ៣៦១D ផ្លូវលេខ៦៨ ភូមិ៥ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ មុខរបរសិស្សវិទ្យាល័យ ឪពុកឈ្មោះ [redacted] "វ" ម្តាយឈ្មោះ [redacted] "វ" នៅលីវ ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់៦ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ពីបទ ប្លន់ (ម៉ូតូ) ប្រព្រឹត្តនៅចំនុចព្រះអង្គដងកើ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រតនៈ, ឈ្មោះ [redacted] សុភាវុធ និងមេធាវីការពារជនជាប់ចោទលោក [redacted] ជីវអេង លោកស្រី [redacted] ធីតា កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ណា។

បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣៥៨ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] រតនៈ និងឈ្មោះ [redacted] សុភាវុធ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៥៨ កបព "ឆ" ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញត្រង់ចំណុចនៃសេចក្តីវិនិច្ឆ័យទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈ តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៥៨ កបព "ឆ" ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៧ "ក្រ.VIសវ" ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] រតនៈ និងឈ្មោ[redacted] សុភាវុធ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៥៨ កបព "ឆ" ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំនុចទី១ នៃសាលក្រមនេះត្រូវកែប្រែបទចោទប្រកាន់ពីបទ ប្លន់ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ទៅជាបទ ប៉ុនប៉ងលួចដោយហិង្សា តាមមាត្រា៣៥៣ មាត្រា៣៥៧ និងមាត្រា៣៦១ នៃក្រមព្រហ្មទណ្ឌវិញ និងកែប្រែទោសដាក់ពន្ធនាគារពីរយៈពេល០៦ឆ្នាំ (ប្រាំមួយឆ្នាំ) មកត្រឹម០៣ឆ្នាំ (បីឆ្នាំ) វិញ យោងតាមមាត្រា១០ នៃក្រមព្រហ្មទណ្ឌ។ ចំណុចផ្សេងពីនេះនៃសាលក្រមត្រូវរក្សាទុកជាបានការដដែល។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] រតនៈ និងឈ្មោះ [redacted] សុភាវុធ តាមនីតិវិធីច្បាប់។

៤-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។ បើកសិទ្ធិឱ្យប្តឹងតវ៉ាតាមកំណត់ច្បាប់។



Scanned by CamScanner

-បានឃើញបណ្ដឹងសាទុក្ខលេខ៤៥ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១៧ "ក្រ.VIសរ" ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចទី២ នៃសេចក្ដីសំរេចទាំងមូល។

-បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា:

១-ទទួលបណ្ដឹងសាទុក្ខលេខ៤៥ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១៧ ក្រVIសរ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

-បានស្ដាប់ក្រឡាបញ្ជីអានសារណាក្នុងបណ្ដឹងសាទុក្ខ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

-បានស្ដាប់សាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ[redacted]រតន: នាពេលសវនាការថា: ខ្លួនពុំមានយោបល់អ្វីសំរាប់ឆ្លើយតបទៅនឹងសារណារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទេ។

-បានស្ដាប់សាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ[redacted]សុភាវុធ នាពេលសវនាការថា: ខ្លួនក៏ពុំមានយោបល់សំរាប់ឆ្លើយតបទៅនឹងសារណារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែរទេ។

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោក[redacted] ចន្ថា មេធាវីការពារឲ្យជនជាប់ចោទទាំងពីរនាពេលសវនាការថា: កូនក្ដីខ្លួនមិនបានប្ដឹងសាទុក្ខទេ មានតែអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តែប៉ុណ្ណោះ ដែលប្ដឹងសាទុក្ខមិនសុខចិត្តនឹងចំណុចទី២។ ការដែលតំណាងមហាអយ្យការសន្និដ្ឋាននាពេលសវនាការនេះថា សាលាឧទ្ធរណ៍សម្រេចសេចក្ដី មិនបានយកសំអាងហេតុមកបញ្ជាក់ឲ្យបានច្បាស់លាស់នោះ គឺជាការមិនត្រឹមត្រូវទេ ពីព្រោះថាកូនក្ដីខ្លួនបានទទួលស្គាល់ការចោទប្រកាន់បានប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ ហើយសាលាឧទ្ធរណ៍បានសម្រេចបន្ថយទោសពី៦ឆ្នាំ មក៣ឆ្នាំ នោះជាការត្រឹមត្រូវហើយ ដោយគ្រាន់តែមិនបានសរសេរសំអាងហេតុខ្លះតែប៉ុណ្ណោះ។ ចំពោះការឃុំខ្លួនកូនក្ដីខ្លួនឈ្មោះ[redacted]រតន: បានលើស១ឆ្នាំហើយ តាំងពីឆ្នាំ២០០៩ មក ឯកូនក្ដីខ្លួនឈ្មោះ[redacted]សុភាវុធ វិញ បានឃុំខ្លួនលើស៥ថ្ងៃហើយមកដល់ពេលនេះ។ ដូច្នេះស្នើសុំក្រុមប្រឹក្សាជំនុំជំរះ សម្រេចតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការដដែល។



Scanned by CamScanner

-បានស្ដាប់សេចក្ដីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថាៈ គ្មានយោបល់អ្វីបន្ថែមទៀតទេ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ និងមេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

**តុលាការកំពូល**

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ៤៥ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឯកឧត្ដមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ១៧ "ក្រ.VIសវ" ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ បានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ៥៨ កបព "ឥ" ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំនុចទី១ នៃសាលក្រមនេះត្រូវកែប្រែបទចោទប្រកាន់ពីបទប្លន់ តាមមាត្រា៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ទៅជាបទ ប៉ុនប៉ងលួច ដោយហឹង្សា តាមមាត្រា៣៥៣ មាត្រា៣៥៧ និងមាត្រា៣៦១ នៃក្រមព្រហ្មទណ្ឌវិញ និងកែប្រែទោសដាក់ពន្ធនាគារពីរយៈពេល០៦ឆ្នាំ (ប្រាំមួយឆ្នាំ) មកត្រឹម០៣ឆ្នាំ (បីឆ្នាំ) វិញ យោងតាមមាត្រា១០ នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា សាលដីកានេះ ពុំមានសំអាងហេតុថា ហេតុអ្វីបានជាត្រូវធ្វើ ការកែប្រែទោសដាក់ពន្ធនាគារ ចំពោះជនជាប់ចោទ ពីរយៈពេល០៦ឆ្នាំ (ប្រាំមួយឆ្នាំ) មកត្រឹម០៣ឆ្នាំ (បីឆ្នាំ) វិញ នោះទេ។ នេះជាមូលហេតុនៃបណ្ដឹងសាទុក្ខតាមមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលគប្បីតុលាការកំពូលបដិសេធសាលដីកា១៧ "ក្រ.VI សវ" ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ ត្រង់ចំណុចកែប្រែទោសដាក់ពន្ធនាគារពីរយៈពេល ០៦ឆ្នាំ(ប្រាំមួយឆ្នាំ) មកត្រឹម០៣ឆ្នាំ(បីឆ្នាំ) នេះចោល។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១៧ "ក្រ.VI សវ" ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្ដីមកនេះ ត្រឹមត្រូវតាមគតិច្បាប់ហើយ លើកលែងតែចំណុចទី២ នៃសេចក្ដីសម្រេច ត្រង់ចំណុចកែប្រែទោសដាក់ពន្ធនាគារពីរយៈពេល០៦ឆ្នាំ (ប្រាំមួយឆ្នាំ) មកត្រឹម០៣ឆ្នាំ (បីឆ្នាំ) ត្រូវបដិសេធចោល។



Scanned by CamScanner

# ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ៤៥ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

២-តម្កល់សាលដីកាសភាព្រហ្មទណ្ឌលេខ១៧ "ក្រ.VIសវ" ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍លើកលែងតែចំណុចទី២ នៃសេចក្តីសម្រេចរបស់សាលដីកានេះ ត្រង់ចំណុចកែប្រែទោសដាក់ពន្ធនាគាររយៈពេល០៦ឆ្នាំ (ប្រាំមួយឆ្នាំ) មកត្រឹម០៣ឆ្នាំ (បីឆ្នាំ) វិញត្រូវបដិសេធចោល។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ២៦១ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីសម្រេចជាថ្មីឡើងវិញ តាមចំណុចទី២ នៃសាលដីកាតុលាការកំពូលនេះ។

៤-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។
រាជធានីភ្នំពេញ ថ្ងៃទី 31 ខែ 5 ឆ្នាំ២០១៣
ក្រឡាបញ្ជី
[redacted]

បានឃើញ
រាជធានីភ្នំពេញ ថ្ងៃទី 31 ខែ 5 ឆ្នាំ២០១៣
ជ.ប្រធានតុលាការកំពូល
អនុប្រធាន
[redacted]



Scanned by CamScanner